ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រៃវែង

សំណុំរឿងព្រហ្មទណ្ឌ

លេខ១១៣/០១

ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩

**សាលក្រមព្រហ្មទណ្ឌ**

**លេខ ៩៧ /១៧(ខ)**

ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០

# ក្នុងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តព្រៃវែង

បានបើកសវនាការជំនុំជម្រះ នៅថ្ងៃពុធ ០៣រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តព្រៃវែង នាថ្ងៃព្រហស្បតិ៍ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង៨:០០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

## ចៅក្រមជំនុំជម្រះ

**លោក [redacted] ចៅក្រម សាលាដំបូងខេត្តព្រៃវែង**

## តំណាងអយ្យការ

**លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តព្រៃវែង**

## ក្រឡាបញ្ជីសវនាការ

**លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង**

## ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ១១៣/០១ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៩ ទៅលើជនជាប់ចោទ៖

១.ឈ្មោះ [redacted] ឈិន ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ ៖ ជាងឡាន សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កំរិតវប្បធម៌ ថ្នាក់ទី៣ ឪពុកឈ្មោះ [redacted] ហឿន (រ) ម្តាយឈ្មោះ [redacted] រិន (ស) ប្រពន្ធឈ្មោះ [redacted] ហ៊ាង(រ) មានកូន០០នាក់ ជានីតិជនទោសពីមុនគ្មាន(ឃុំថ្ងៃទី២៨.០៣.២០១៩)។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ។

២-ឈ្មោះ [redacted] សុឌី ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ៖ ជាងជួសជុលរថយន្ត សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កំរិតវប្បធម៌ ថ្នាក់ទី១០ថ្មី ឪពុកឈ្មោះ [redacted] សុភាព (រ) ម្តាយឈ្មោះ [redacted] សំអូន (ស) ប្រពន្ធឈ្មោះ [redacted] ហ៊ាង (រ) មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន(ឃុំថ្ងៃទី២៨.០៣.២០១៩)។

៣-ឈ្មោះ [redacted] ដានី ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរ ៖ កសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូ [redacted] ខេត្តព្រៃវែង កំរិតវប្បធម៌ ថ្នាក់ទី១២ថ្មី ឪពុកឈ្មោះ [redacted] សុភាព (រ) ម្តាយឈ្មោះ [redacted] សំអូន (ស) ប្រពន្ធឈ្មោះ [redacted] ចាន់នុត (រ) មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន(ឃុំថ្ងៃទី២៨.០៣.២០១៩) ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ប្តឹងបរិហាបង្កាច់កេរ្តិ៍ និងបទ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅចំណុចភូមិគោកសណ្តែក ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃ២៣ ខែមីនា ឆ្នាំ២០១៩ បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣១១.៣១២ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។

តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ១៦៤៥ ជស.ព្រទ/១៩ ចុះថ្ងៃចន្ទ ១៤រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ។

បានឃើញដីកាសន្និដ្ឋានជាស្ថាពរលេខ១៥៦ អយ ចុះថ្ងៃពុធ ១០រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តព្រៃវែង ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៧៩/២០១៩ អយ ចុះថ្ងៃពុធ ៧រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រៃវែង ។

បានឃើញ ដីកាសម្រេចបំបែកសំណុំរឿងព្រហ្មទណ្ឌលេខ៧២៧/២០២០ ចុះថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តព្រៃវែង។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ៩៦/២០២០ ចុះថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តព្រៃវែង។

## **ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖**

កាលពីអំឡុងចុងឆ្នាំ២០១៨ ជនរងគ្រោះឈ្មោះ [redacted] វ៉ាវុធ បានយករថយន្តម៉ាកព្រូស (TOYOTA PRIUS) ទៅដាក់បញ្ចាំឲ្យជនជាប់ចោទឈ្មោះ [redacted] ឈិន ក្នុងតម្លៃ $៣០០០(បីពាន់)ដុល្លារអាមេរិក ក្រោយមករថយន្តនេះក្រោយពីមានការឯកភាពពីជនរងគ្រោះឈ្មោះ [redacted] វ៉ាវុធ ជនជាប់ចោទឈ្មោះ [redacted] ឈិន ក៏បានជួលឲ្យជនជាតិចិន។ ក្រោយមករថយន្តនោះក៏ខូចម៉ាស៊ីនត្រជាក់ ភ្ញៀវជនជាតិចិននោះក៏បានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ឈិន ឲ្យមកយករថយន្តទៅជួសជុល ជនជាប់ចោទឈ្មោះ [redacted] ឈិន មិនទាន់បានយករថយន្តផង ក៏ត្រូវជនរងគ្រោះឈ្មោះ [redacted] វ៉ាវុធ ទៅយកបាត់។ លុះមកដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៩យប់ ជនជាប់

ចោទឈ្មោះ [redacted] ឈិនបានបើកប្រព័ន្ធផែនទីតាមដាន(GPS) ក៏ឃើញរថយន្តម៉ាកព្រូស(TOYOTA PRIUS) នោះ ស្ថិតនៅលើផ្លូវជាតិលេខ១ ដោយបានឃើញដូចនេះ ជនជាប់ចោទឈ្មោះ [redacted] ឈិន ក៏បានទូរស័ព្ទទៅប្រាប់ជនជាប់ចោទឈ្មោះ [redacted] សុនី ថាមានចោរលួចរថយន្តរបស់ខ្លួន ឲ្យជួយស្ទាក់ចាប់ផង បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] សុនី ក៏បានទូរស័ព្ទបន្តទៅជនជាប់ចោទឈ្មោះ [redacted] ផានី ដែលរស់នៅភូមិសឹង ឃុំកំពង់សឹង ស្រុកព្រះស្ដេច ខេត្តព្រៃវែង ឲ្យជួយស្ទាក់ចាប់ ហើយជនជាប់ចោទឈ្មោះ [redacted] ផានី ក៏បានទូរស័ព្ទទៅមេប៉ុស្តិ៍កំពង់សឹងឲ្យជួយអន្តរាគមន៍ស្ទាក់ចាប់ ហើយលោកមេប៉ុស្តិ៍ក៏បានដឹកនាំកំលាំងប្រតិបត្តិការណ៍ រហូតដល់មានការផ្ទុះអាវុធបាញ់ទៅលើជនរងគ្រោះឲ្យមានរបួសធ្ងន់ និងស្លាប់នៅមន្ទីរពេទ្យ ក្រោយពីហេតុការណ៍នេះកើតរួចសមត្ថកិច្ចនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែងក៏បានចុះប្រតិបត្តិការ និងចាប់ឃាត់ខ្លួនជនជាប់ចោទ និងវត្ថុតាង បង្កសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈិន នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុនី នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផានី នាពេលសវនាការ

-បានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] គន្ធា,ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] សុខខី នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់អ្នកស្នើសុំរថយន្តឈ្មោះ [redacted] លីណា នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់មន្ត្រីនគរបាល យុត្តិធម៌ នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] រតនៈ នាពេលសវនាការ

-បានស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ ឈ្មោះ [redacted] វិន នាពេលសវនាការ

-បានស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ ឈ្មោះ [redacted] ប៊ុន ទីឃីយ៉ាត់ ហៅយ៉ាត នាពេលសវនាការ

-បានស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ ឈ្មោះ [redacted] វណ្ណារិទ្ធ នាពេលសវនាការ

-បានស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ ឈ្មោះ [redacted] ប៊ុនសារៈ នាពេលសវនាការ

-បានស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ ឈ្មោះ [redacted] ឈុនឡាយ នាពេលសវនាការ

## តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

ក្រោយពីបានស្ដាប់ការសួរដេញដោលក្នុងពេលសវនាការឃើញថា កាលពីអំឡុងចុងឆ្នាំ ២០១៨ ជនរងគ្រោះឈ្មោះ [redacted] រ៉ាវុធ បានយករថយន្តម៉ាកព្រូស(TOYOTA PRIUS) ទៅដាក់បញ្ចាំឲ្យជនជាប់ចោទឈ្មោះ [redacted] ឈិន ក្នុងតម្លៃ $៣០០០(បីពាន់)ដុល្លារអាមេរិក ក្រោយមករថយន្តនេះក្រោយពីមានការឯកភាពពីជនរងគ្រោះឈ្មោះ [redacted] រ៉ាវុធ ជនជាប់ចោទឈ្មោះ [redacted] ឈិន ក៏បានជួលឲ្យជនជាតិចិន។ ក្រោយមករថយន្តនោះក៏ខូចម៉ាស៊ីនត្រជាក់ ភ្ញៀវជនជាតិចិននោះក៏បានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ឈិន ឲ្យមកយករថយន្តទៅជួសជុល ជនជាប់ចោទឈ្មោះ [redacted] ឈិន មិនទាន់បានយករថយន្តផង ក៏ត្រូវជនរងគ្រោះឈ្មោះ [redacted] រ៉ាវុធ ទៅយកបាត់។ លុះមកដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៩យប់ ជនជាប់ចោទឈ្មោះ [redacted] ឈិនបានបើក



Scanned with CamScanner

ប្រព័ន្ធផែនទីតាមដាន(GPS) ក៏ឃើញរថយន្តម៉ាកព្រូស(TOYOTA PRIUS) នោះ ស្ថិតនៅលើផ្លូវជាតិលេខ១ ដោយបានឃើញដូចនេះ ជនជាប់ចោទឈ្មោះ [redacted] ឈិន ក៏បានទូរស័ព្ទទៅប្រាប់ជនជាប់ចោទឈ្មោះ [redacted] សុខី ថាមានចោរលួចរថយន្តរបស់ខ្លួន ឲ្យជួយស្ទាក់ចាប់ផង បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] សុខី ក៏បានទូរស័ព្ទបន្តទៅជនជាប់ចោទឈ្មោះ [redacted] ផានី ដែលរស់នៅភូមិសឹង ឃុំកំពង់សឹង ស្រុកព្រះស្ដេច ខេត្តព្រៃវែង ឲ្យជួយស្ទាក់ចាប់ ហើយជនជាប់ចោទឈ្មោះ [redacted] ផានី ក៏បានទូរស័ព្ទប្ដឹងទៅមេប៉ុស្តិ៍កំពង់សឹងឲ្យជួយអន្តរាគមន៍ស្ទាក់ចាប់ ហើយលោកមេប៉ុស្តិ៍ក៏បានដឹកនាំកំលាំង ប្រតិបត្តិការណ៍ រហូតដល់មានការផ្ទុះអាវុធបាញ់ទៅលើជនរងគ្រោះឲ្យមានរបួសធ្ងន់ និងស្លាប់នៅមន្ទីរពេទ្យ។ ដូច្នេះនៅក្នុងរឿងនេះគឺកើតចេញអំពីការបរិហាបង្កាច់កេរ្តិ៍ ហើយការបរិហាបង្កាច់កេរ្តិ៍នេះឯងដែលនាំឲ្យកើតមាននូវការ ផ្ទុះអាវុធកើតឡើងរហូតមានស្លាប់មនុស្សដែលជាអំពើនៃបទឧក្រិដ្ឋ ដែលកើតចេញពីជនជាប់ចោ.ទទាំង ០៣ នាក់នេះ។

ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្ដន្ទាទោសតាមច្បាប់។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ឈិន ធ្វើសេចក្ដីសន្និដ្ឋាន**

តាមអង្គហេតុ និងការសួរដេញដោល នៅពេលសវនាការ ឃើញថា កូនក្ដីរបស់ខ្លួនជាជនរងគ្រោះ ដូច្នេះសុំឲ្យតុលាការពិចារណាដោយហេតុផលថា អង្គហេតុ និងការសួរដេញដោល នៅពេលសវនាការ មកនេះ ជនរងគ្រោះ និងកូនក្ដីខ្លួនមានទំនាក់ទំនងគ្នា រហូតធ្វើឲ្យកូនក្ដីខ្លួនយកឡានទៅជួលឲ្យជនជាតិចិនគឺជាការបង្កើតកិច្ចសន្យាមួយដែលធ្វើឡើងស្របច្បាប់ ។ ការប្ដឹងរបស់កូនក្ដីខ្លួនគឺមានសិទ្ធិប្ដឹងទៅគ្រប់សមត្ថកិច្ច ដូចនេះសកម្មភាពដែលកូនក្ដីខ្លួន ធ្វើពុំអាចចាត់ទុកថាជាអំពើប្ដឹងបរិហាបង្កាច់កេរ្តិ៍ និងបទញុះញង់ឲ្យប្រព្រឹត្ត បទឧក្រិដ្ឋជាអាទិ៍បានឡើយ ព្រោះ សកម្មភាពដែលកូនក្ដីខ្លួនបានធ្វើគឺគ្រាន់តែជាការប្ដឹងតៗគ្នាតែប៉ុណ្ណោះ ដូចនេះក្នុងរឿងនេះរាខ្វះធាតុផ្សំ នៃបទល្មើសបានសេចក្ដីថា បើខ្វះចំណុចណាមួយ មិនអាចចាត់ទុកថាជាបទល្មើសបានឡើយ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ឈិន ស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្ដីខ្លួនរួចខ្លួនពីបទចោទប្រកាន់ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] សុខី បាន ធ្វើសេចក្ដីសន្និដ្ឋាន**

តាមអង្គហេតុ និងការសួរដេញដោល នៅពេលសវនាការនេះខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] សុខី ឃើញថា កូនក្ដីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ ដោយហេតុថាកូនក្ដីរបស់ខ្លួនគ្រាន់តែជាអ្នកជួយយកអាសារគេតែប៉ុណ្ណោះ ដោយគ្រាន់តែរាយការណ៍ក្នុងការជួយឃាត់ឡាន ព្រោះកូនក្ដីខ្លួន ជាបងប្អូនបង្កើតនឹងគ្នា ដូច្នេះនៅពេលដែលមានការពឹងពាក់បងប្អូនទាំងពីរ តែងតែជួយគ្នាទៅវិញទៅមក ការរាយការណ៍បន្តមកសមត្ថកិច្ច ដើម្បីជួយស្ទាក់ឡាន ដែលជនរងគ្រោះបើកបរពីភ្នំពេញមកព្រៃវែង នេះពុំអាចចាត់ទុកជាអំពើប្ដឹងបរិហាបង្កាច់កេរ្តិ៍និងញុះញង់ឲ្យប្រព្រឹត្តិបទឧក្រិដ្ឋជាអាទិ៍បានឡើយ ព្រោះអ្វីដែលកូនក្ដីខ្លួន បានធ្វើកន្លងមកនេះ គឺពួកគាត់ទាំងពីរនាក់បងប្អូន ពុំដឹងថារថយន្តដែលជនរងគ្រោះ កំពង់ជិះ



Scanned with CamScanner

នេះជារបស់គាត់ រឺយ៉ាងណាទេ ព្រោះឈ្មោះ [redacted] ឈិន ប្រាប់ថាជាចោរ ដូចនេះក្នុងសង្គម ខ្មែរបច្ចុប្បន្ន បើសិនជាមានអំពើ លួចកើតឡើងហើយ ប្រជាពលរដ្ឋម្នាក់មានសិទ្ធិរាយការណ៍ជូនសមត្ថកិច្ចដើម្បីបង្ក្រាបអំពើលួច បើតាមសកម្មភាពរបស់កូនក្តីខ្លួនពុំអាចចាត់ទុកជាបទល្មើសទេ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] សុខី ស្នើសុំឲ្យតុលាការពិចារណា សម្រេចឲ្យកូនក្តីខ្លួន រួចខ្លួនពីបទចោទប្រកាន់ ។

- ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទទាំង០៣នាក់
- ក្រោយពីបានស្តាប់អំណាន ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់អំណាន ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ ឲ្យជនជាប់ចោទទាំង០៣នាក់
- ក្រោយពីបាន ពិនិត្យ ភស្តុតាង និងឯកសារនានា
- ក្រោយពីបាន ពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សាលាដំបូងខេត្តព្រៃវែង**

## **យល់ឃើញថា**

តាមអង្គហេតុ និងឯកសារនានា បញ្ជាក់ថា ៖ កាលពីអំឡុងចុងឆ្នាំ២០១៨ ជនរងគ្រោះឈ្មោះ [redacted] រ៉ាវុធ ពិតជាបានយករថយន្តម៉ាកព្រូស(TOYOTA PRIUS) ទៅដាក់បញ្ចាំឲ្យជនជាប់ចោទឈ្មោះ [redacted] ឈិន ក្នុងតម្លៃ $៣០០០(បីពាន់)ដុល្លារអាមេរិក ក្រោយមករថយន្តនេះក្រោយពីមានការឯកភាពពីជនរងគ្រោះឈ្មោះ [redacted] រ៉ាវុធ ជនជាប់ចោទឈ្មោះ [redacted] ឈិន ក៏បានជួលឲ្យជនជាតិចិន។ ក្រោយមករថយន្តនោះក៏ខូចម៉ាស៊ីនត្រជាក់ ភ្ញៀវជនជាតិចិននោះក៏បានទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ឈិន ឲ្យមកយករថយន្តទៅជួសជុល ជនជាប់ចោទឈ្មោះ [redacted] ឈិន មិនទាន់បានយករថយន្តផង ក៏ត្រូវជនរងគ្រោះឈ្មោះ [redacted] រ៉ាវុធ ទៅយកបាត់។ លុះមកដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១៩យប់ ជនជាប់ចោទឈ្មោះ [redacted] ឈិន បានបើកប្រព័ន្ធផែនទីតាមដាន(GPS) ក៏ឃើញរថយន្តម៉ាកព្រូស(TOYOTA PRIUS) នោះ ស្ថិតនៅលើផ្លូវជាតិលេខ១ ដោយបានឃើញដូចនេះ ជនជាប់ចោទឈ្មោះ [redacted] ឈិន ក៏បានទូរស័ព្ទទៅប្រាប់ជនជាប់ចោទឈ្មោះ [redacted] សុខី ថាមានចោរលួចរថយន្តរបស់ខ្លួន ឲ្យជួយស្ទាក់ចាប់ផង បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] សុខី ក៏បានទូរស័ព្ទបន្តទៅជនជាប់ចោទឈ្មោះ [redacted] ផានី ដែលរស់នៅភូមិសឹង ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ឲ្យជួយស្ទាក់ចាប់ ហើយជនជាប់ចោទឈ្មោះ [redacted] ផានី ក៏បានទូរស័ព្ទប្តឹងទៅមេប៉ុស្តិ៍កំពង់សឹងឈ្មោះ [redacted] ឡាឌីន ឲ្យជួយអន្តរាគមន៍ស្ទាក់ចាប់ ហើយលោកមេប៉ុស្តិ៍ក៏បានដឹកនាំកំលាំង ប្រតិបត្តិការណ៍រួមមានឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] វិន ជាសមត្ថកិច្ច រហូតដល់មានការផ្ទុះអាវុធបាញ់ទៅលើជនរងគ្រោះឲ្យមានរបួសធ្ងន់ និងស្លាប់ នៅមន្ទីរពេទ្យបាភ្នំ ដែលស្តែងឲ្យឃើញថា ជនជាប់ចោទទាំងបី ពិតជាបានប្រព្រឹត្តអំពើ បរិហាបង្កាច់កេរ្តិ៍ និងញុះញង់ឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋជាអាទិ៍ពិតប្រាកដមែន ។



Scanned with CamScanner

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈិន បានឆ្លើយថា ៖ កាលពីខែមិនចាំអំឡុងចុងឆ្នាំ២០១៨ ជនរងគ្រោះឈ្មោះ [redacted] វ៉ាវុធ បានយករថយន្តម៉ាកព្រូស(TOYOTA PRIUS) ទៅដាក់បញ្ចាំឲ្យខ្លួន ក្នុងតម្លៃ $៣០០០(បីពាន់)ដុល្លារអាមេរិក ក្រោយមករថយន្តនេះក្រោយពីមានការឯកភាពពីជនរងគ្រោះឈ្មោះ [redacted] វ៉ាវុធ និងខ្លួន ក៏បានជួលឲ្យជនជាតិចិន។ ក្រោយមករថយន្តនោះក៏ខូចម៉ាស៊ីនត្រជាក់ ភ្ញៀវជនជាតិចិននោះក៏បានទូរស័ព្ទទៅប្រាប់ខ្លួនឲ្យមកយករថយន្តទៅជួសជុល ខ្លួនមិនទាន់បានយករថយន្តផង ក៏ត្រូវជនរងគ្រោះឈ្មោះ [redacted] វ៉ាវុធ ទៅយកបាត់ ខ្លួនក៏បានប្តឹងទៅខណ្ឌពោធិ៍សែនជ័យ។ លុះមកដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១៩ យប់ ខ្លួន បានបើកប្រព័ន្ធផែនទីតាមដាន(GPS) ក៏ឃើញរថយន្តម៉ាកព្រូស(TOYOTA PRIUS) នោះស្ថិតនៅលើផ្លូវជាតិលេខ១ ដោយបានឃើញដូចនេះ ខ្លួន ក៏បានទូរស័ព្ទទៅប្រាប់បងឈ្មោះ [redacted] សុខី ថាមានគេយករថយន្តរបស់ខ្លួន ឲ្យជួយស្ទាក់ចាប់ផង ពេលនោះបង សុខី ក៏បានជួយតាម រហូតមកតាមដល់ទឹកដីស្រុកបាភ្នំ គឺភូមិគោកសណ្តែក ឃុំរក្សជ័យ ក៏ឃើញឡាននោះធ្លាក់ទៅផ្នែកម្ខាងនៃផ្លូវ និងមានឈាមនៅទីនោះ ដោយឈ្មោះ [redacted] វ៉ាវុធ មានរបួស។ ខ្លួនមិនបាននិយាយថា ចោរលួចឡានខ្លួនទេ តែមិនដឹងបង [redacted] សុខី គាត់និយាយថាម៉េចទេ។ ខ្លួនមិនដឹងថា [redacted] ផាន់ សុខី និយាយប្តឹងទៅតទៀតយ៉ាងណាទេ។

ឡានដែល វ៉ាវុធ យកដាក់បញ្ចាំមិនទាន់បានឡានទេ គឺយកលុយពេលព្រឹក បានឡាននៅពេលល្ងាច។.

ពេលដែលខ្ញុំជួលឡានព្រូសនោះ គឺមានធ្វើកិច្ចសន្យាជួលដែរ។ ពេលដែល [redacted] វ៉ាវុធ យកឡានខ្លួននោះ ពេលខ្លួនទូរស័ព្ទទៅ [redacted] សុខី គឺគាត់នៅច្បារអំពៅ។ ឡានព្រូសនោះជារបស់ឈ្មោះ [redacted] វ៉ាវុធ តែមិនដឹងថា [redacted] វ៉ាវុធ បានមកពីណាទេ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខី បានឆ្លើយថា: កាលថ្ងៃកើតហេតុឈ្មោះ [redacted] ឈិន បានទូរស័ព្ទ មកខ្លួនឲ្យជួយស្ទាក់ឡាន ដោយថា ចោរលួចទៅ ខ្លួនក៏សួរថា ឡានម៉ាកអី? គាត់ប្រាប់ថា ម៉ាក ព្រូស មានដាក់ឡាសែរពីលើ។ ពេលខ្លួនទទួលដំណឹងនោះគឺខ្លួននៅព្រែកប្រា ពេលនោះខ្លួនក៏ទៅភ្លាមដល់ច្បារអំពៅ ហើយខ្លួនក៏ឃើញឡាននោះនៅពេលខ្លួនដល់មុខវិទ្យាល័យច្បារអំពៅ ខ្លួនក៏ប្រាប់ទៅ ឈិន វិញពីភិនភាគនោះ។ ពេលខ្លួនទៅនោះមានគ្នា ៣ នាក់ គឺឈ្មោះ សារ: និងឈ្មោះ ឡាយ។ ពេលខ្លួនជួបគ្នាជាមួយឈ្មោះ [redacted] ឈិន នោះ គឺជួបនៅកែងផ្លូវស្រាបៀរថៃគ័រ ហើយឈ្មោះ [redacted] ឈិន បានឡើងជិះឡានខ្លួន ដេញតាមឡានព្រូសនោះ ហើយខ្លួនក៏ទូរស័ព្ទទៅបង [redacted] ផានី ថាឲ្យជួយស្ទាក់ឡាន និងប្តឹងទៅឈ្មោះ [redacted] ឡាឌីន ជាប៉ូលីសប៉ុស្តិ៍កំពង់សឹង ពេលនោះខ្លួនក៏ជួបឈ្មោះ [redacted] ឡាឌីន តាមទូរស័ព្ទថា បងជួយស្ទាក់ឡានព្រូសផង ពេលនោះ ជាឡាឌីន ក៏ថា ចាំគាត់ជួយ និងប្រាប់កំលាំងឲ្យជួយ រហូតមកតាមដល់ទឹកដីស្រុកបាភ្នំ គឺភូមិគោកសណ្តែក ឃុំរក្សជ័យ ក៏ឃើញឡាននោះធ្លាក់ទៅផ្នែកម្ខាងនៃផ្លូវ និងមានឈាមនៅទីនោះផង ដោយឈ្មោះ [redacted] វ៉ាវុធ មានរបួស(មិនដឹងរស់ ឬស្លាប់ទេ) និងមានអាវុធផងដែរ។ ពេលទៅដល់កន្លែងកើតហេតុនោះឈ្មោះ [redacted] ឡាឌីន សួរថា នណាម្ចាស់ឡាន ហើយសួរថា អាអូនហ្នឹងអីចោរ? ពេលនោះឈ្មោះ [redacted] ឈិន ឆ្លើយថា ហ្នឹងហើយបង។ នៅក្នុងឡានដែលជិះជាមួយខ្លួននោះឈ្មោះ [redacted] ឈិន មិនបាននិយាយជាមួយ [redacted] ផានី ឬឈ្មោះ [redacted] ឡាឌីន ទេ។

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផានី បានឆ្លើយថាៈ ខ្លួន និងឈ្មោះ [redacted] សុខី ត្រូវជាបងប្អូនបង្កើតនឹងគ្នា។ ថ្ងៃកើតហេតុឈ្មោះ [redacted] សុខី បានទូរស័ព្ទមកខ្លួនសួររកលេខប្រធានប៉ុស្តិ៍ឈ្មោះ [redacted] ឡាឌីន ហើយខ្លួនក៏សួរនាំទៅ [redacted] ឡាឌីន ថាប្អូនខ្លួនមានគេទៅអត់ ហើយ [redacted] ឡាឌីន សួរថា ឡាននោះជាឡានរបស់នណា? ខ្លួនថាជាឡានប្អូនខ្លួន ពេលនោះ ឡាឌីន ក៏ឲ្យខ្លួនឡើងមកកែងកំពង់សឹងមក ខ្លួនក៏មកភ្លាម ហើយជួប ឡាឌីន និងហុចទូរស័ព្ទឲ្យ [redacted] សុខី និយាយជាមួយ។ ពេលឃើញឡានដែលមានភិនភាគដូចប្អូនប្រាប់ ឈ្មោះ [redacted] ឡាឌី ឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] រិន បានជិះឡានជាមួយគ្នាដេញតាម ខ្ញុំក៏ចេះតែសួរ ឈ្មោះ [redacted] ឡាឌីន ថា បងឯងកុំភ័យគេចេះធ្វើការហើយ តាមផ្លូវប៉ូលីសក៏នាំគ្នាស្រែកថាឲ្យឈប់ ហើយបើកឡានជារបាំង និងលើកដៃរាឲ្យឈប់ តែមិនឈប់ ទើបសមត្ថកិច្ចបាញ់តែម្តង។ ក្រោយសមត្ថកិច្ចបង្ក្រាបរួចទើប សេង ឈិន និង ផាន់ សុខី មកដល់។

ពេលខ្លួនឃើញជនរងគ្រោះនោះមិនទាន់ស្លាប់ទេ។ នៅពេលកើតហេតុមិនមានសមត្ថកិច្ចណាផ្ទុះអាវុធក្រៅពី [redacted] រតនៈ ឈ្មោះ [redacted] រិន និង [redacted] ឡាឌីន នោះទេ។ ក្រោយមកក៏មានផ្ទុះអាវុធចំនួន ០២គ្រាប់ ទៀត។

តាមអំណានចម្លើយរបស់ឈ្មោះ [redacted] គន្ធា (ម្តាយជនរងគ្រោះ) ,ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] សុខខី បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថាៈ កាលពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១២ទាបភ្លឺ ឈានចូលថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៩ ខ្លួនបានទទួលទូរស័ព្ទពីមន្ទីរពេទ្យស្រុកបាភ្នំថា ជនរងគ្រោះគ្រោះថ្នាក់ចរាចរណ៍ ហើយបានស្លាប់នៅមន្ទីរពេទ្យ ។ ពួកខ្លួនក៏បានសួរបញ្ជាក់ ពីភិនភាគរបស់ជនរងគ្រោះ និងសួរថាបានលេខទូរស័ព្ទមកពីណា ពេលនោះគ្រូពេទ្យឆ្លើយថា បាន់លេខទូរស័ព្ទមកពីមិត្តភក្តិក្នុងហ្វេសប៊ុក ។ នៅវេលាម៉ោងប្រហែល ២ និង ៣០នាទីយប់ ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៩ ពួកខ្លួនបានធ្វើដំណើរពីភ្នំពេញ ហើយទៅមន្ទីពេទ្យបង្អែក មុខកន្លែងនគរបាលស្រុកបាភ្នំ នៅវេលាម៉ោងប្រហែល ៥ទៀបភ្លឺ ។ ពួកខ្លួនបានឃើញសាកសព នៅក្នុងឡានពេទ្យនោះ ។ បន្ទាប់មកពួកខ្លួនគេទូរស័ព្ទទៅឈ្មោះ [redacted] ខេមរិន្ទ ថា [redacted] រ៉ាវុទ្ធ ត្រូវបានគេបាញ់ស្លាប់ ហើយឱ្យពួកខ្លួនមកស្រុកបាភ្នំ ។ ក្រោយមកមានសាធារណៈជន ប្រាប់ខ្លួនថា ជនដៃដល់គឺជាកូនរបស់ឈ្មោះ [redacted] សុខ ។ ពួកខ្លួនបានចាំរហូតដល់ម៉ោង ១រសៀលថ្ងៃខែឆ្នាំដដែល ទើបខាងមន្ទីរពេទ្យបង្អែកស្រុកបាភ្នំ ដឹកសាកសពទៅកាន់មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង ដើម្បីធ្វើកោសលវិច័យ ដោយពួកខ្លួនជិះរថយន្តផ្សេងអមជាមួយរថយន្តពេទ្យ ។ នៅអំឡុងពេលធ្វើកោសលវិច័យ ពួកខ្លួនបានឈរមើលការធ្វើកោសលវិច័យ ហើយបានឃើញប្រហោងចូល ៥កន្លែង និងធ្លាយចេញចំនួន ២កន្លែង ។ នៅវេលាម៉ោង ៣និង ៣០នាទី កោសលវិច័យបានបញ្ចប់ ហើយពួកខ្លួនបានរៀបចំបន្ទប់ដឹកសាកសព ដើម្បីដឹកបញ្ជូនមកភ្នំពេញវិញ ។ ពួកខ្លួនសំណូមពរទាមទារសំណងចំនួន ១០០,០០០(ដប់ម៉ឺនដុល្លា)អាមេរិច និងចាត់ការតាមនីតិវិធីច្បាប់ ព្រោះជនរងគ្រោះមានចំណូលពី ២,០០០(ពីពាន់)ទៅ ៣,០០០(បីពាន់) ដុល្លាអាមេរិច ហើយជាបុគ្គលដែលមានកាតព្វកិច្ចផ្គត់ផ្គង់គ្រួសារ ។ ពួកខ្លួនស្នើសុំរថយន្តដែលមានស្លាកលេខសម្គាល់ ២AF-២៦៧៩ ម៉ាកព្រូស(PRIUS) ពណ៌ទឹកមាសលេខតួ JTDKB២០U៦៧៧៦២៨៨៦០ លេខម៉ាស៊ីន ១៦៧០៨០ ផលិតឆ្នាំ២០០៧ ដែលជាកម្មសិទ្ធរបស់ជនរងគ្រោះឈ្មោះ [redacted] រ៉ាវុទ្ធ ។ ខ្លួនមិនបានដឹងលុយចំនួន



Scanned with CamScanner

៣,០០០(បីពាន់)ដុល្លាអាមេរិច នោះទេ ។ ខ្លួនមិនប្រគល់ប្រាក់ចំនួន ៣,០០០(បីពាន់)ដុល្លាអាមេរិច ដែលឈ្មោះ [redacted] ឈិន ទាមទារពាក់ព័ន្ធនិងការស្នើសុំរថយន្តព្រួសខាងលើនោះទេ។ ខ្លួនសូមភ្ជាប់ឯកសារពាក់ព័ន្ធនិងប្រាក់ចំនួន ៣,០០០ (បីពាន់)ដុល្លាអាមេរិច បន្ថែមទៀត។

តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] រតនៈ បានឆ្លើយថាៈ ខ្លួនជាប៉ូលីស ទទួលបន្ទុកអន្តោប្រវេសន៍។ កាលថ្ងៃកើត ហេតុអធិការរងស្រុកព្រះស្តេចឈ្មោះ [redacted] ស៊ិយ បានឲ្យខ្ញុំសហការជាមួយ [redacted] ឡាឌីន ប្រតិបត្តការចាប់ចោរលួចឡាន ពេលខ្ញុំឃាត់ឡានព្រួសមិនឈប់ ខ្ញុំក៏បានបាញ់ចំនួន ៣.៤ គ្រាប់ [redacted]វិន បាញ់ចំនួន ២គ្រាប់។ ជនរងគ្រោះមិនបានស្លាប់នៅកន្លែងកើតហេតុទេ គឺស្លាប់នៅពេទ្យខេត្ត ពេលយកទៅពេទ្យ គឺខ្ញុំយកទៅពេទ្យស្រុក ចំណែក [redacted]វិន យកទៅពេទ្យខេត្ត។

តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] វិន បានឆ្លើយថាៈ ខ្លួនជាប៉ូលីសប៉ុស្តិ៍កំពង់សឹង។ ថ្ងៃកើតហេតុមេប៉ុស្តិ៍ឈ្មោះ [redacted] ឡាឌីន បានទូរស័ព្ទមកថាមកជួយសហការប្រតិបត្តការចាប់ចោរលួចឡាន។ ខ្ញុំបានបាញ់ចំនួន ០១ គ្រាប់ ឡើងលើ។ ពេលបាញ់ខ្ញុំមិនដឹងត្រូវ ឬមិនត្រូវទេ។ អ្នកដែលកាន់អាវុធមានខ្ញុំ ឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] ឡាឌីន។

តាមចម្លើយរបស់ឈ្មោះ [redacted] លីណា ដែលជាម្ចាស់ឡាន បានឆ្លើយថាៈ ឡានម៉ាកព្រួស នេះខ្លួនទិញអស់រយៈពេល ៥ឆ្នាំមកហើយ ដោយទិញរំលោះពីក្រុមហ៊ុនពិភពថ្មី។ កន្លងមករូបខ្លួនធ្លាប់មានទំនាក់ទំនងជាមួយឈ្មោះ [redacted] រ៉ាវុធ តាំងពី ៥ឆ្នាំ មុន ជាលក្ខណៈសង្សានឹងគ្នា ហើយក៏ធ្លាប់ឈ្មោះ [redacted] រ៉ាវុធ លួចយកឡានម៉ាកព្រួសនេះទៅដាក់បញ្ចាំចំនួន ៣.០០០៛(បីពាន់)ដុល្លារអាមេរិកឲ្យទៅគេនៅម្តុំផ្សារឃ្លាំងរំសេវ ម្តងហើយ រួចខ្លួនបានដើររកក៏ឃើញហើយដឹងពីកន្លែងដាក់បញ្ចាំ ក៏ទៅលោះយកមកវិញ ហើយក៏បែកគ្នាទៅ ក្រោយមកមុនពេលកើតហេតុប្រហែលចំនួន ០២ខែ ឈ្មោះ [redacted] រ៉ាវុធ ក៏មកសុំទិញឡានម៉ាកព្រួសនេះពីខ្លួន ក្នុងតម្លៃ១២០០០ ដោយសុំកក់តែ២៥០០$ នៅខ្វះចំនួន ៩៥០០ ដុល្លារអាមេរិកទៀត ។ បច្ចុប្បន្នឡាននេះខ្លួនកំពុងបន្តទៅប្រាក់រំលោះឲ្យក្រុមហ៊ុនបូរីពិភពថ្មី រហូតដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ទើបចប់ជាស្ថាពរ ដូចមានឯកសារបានដាក់ជូនតុលាការនៅក្នុងពាក្យសុំ របស់ខ្លួនមានដូចជា ប័ណ្ណសម្គាល់យានយន្ត កាលវិភាគបង់ប្រាក់រំលោះ និងលិខិតលក់រថយន្ត។

តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ទីយីយ៉ាត់ ហៅ យ៉ាត បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ ម៉ោងប្រហែល៨យប់ ខ្លួនបានទៅលេងផ្ទះដែលជាស្ថានីយ៍សាំងរបស់ឈ្មោះ [redacted] រតនៈ។ ពេលនោះ ទូរស័ព្ទរបស់ [redacted] រតនៈ បានរោទិ៍ ហើយបន្ទាប់ពីបញ្ចប់ការសន្ទនាតាមទូរស័ព្ទ ឈ្មោះ [redacted] រតនៈ ក៏បានប្រាប់ខ្លួន គោះទៅកំពង់សឹងមួយភ្លែត ដើម្បីជួយស្ទាក់ឡាន ព្រោះមានគេលួចឡានមកពីភ្នំពេញ ហើយខ្លួនក៏បានឡើងឡាន ប្រភេទ Pick up ស្លាកលេខនគរបាល ពណ៌សជាមួយ [redacted] រតនៈទៅ ដោយមានគ្នា២ (ពីរ)នាក់ ខ្លួនជាមួយនិង [redacted] រតនៈ។ ខ្លួននិង [redacted] រតនៈ បានចេញពីផ្ទះទៅ កែងកំពង់សឹងប្រហែលម៉ោង៨ះ១០នាទី បានជួបជាមួយសមត្ថកិច្ច៤ (បួន)នាក់ មានឈ្មោះ [redacted] ឡាឌីន [redacted]វិន និង២នាក់ទៀត ដែលម្នាក់ឈ្មោះ [redacted] ផានី និងម្នាក់ទៀតមិនស្គាល់ឈ្មោះឡើយ។ [redacted] ឡាឌីន [redacted] រតនៈ និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ពាក់ឯកសណ្ឋានប៉ូលីស ហើយកាន់កាំភ្លើងខ្លី ហើយឈ្មោះ [redacted] វិន និង [redacted] ផានី ឈរនៅកែងម្ខាងទៀតលើផ្លូវជាតិលេខ១។ ពេលទៅដល់ខ្លួនបានឈរនៅជិតឡានហើយ [redacted] រតនៈ បាន

ដើរចុះដើរឡើងនិងមានការនិយាយជាមួយ [redacted] ឡាឌីន ។ ខ្លួននិងអ្នកផ្សេងទៀត នៅចាំរហូត៣០ទៅ៤០នាទី [redacted] ឡាឌីន បានទទួលដំណឹងថា ឡាននោះបត់តាមក្រោមស្ពានទៅតាម ព្រៃវែងវិញហើយ។ បន្ទាប់មក [redacted] ឡាឌីន បានហៅឡើងឡាន ហើយ [redacted] រតនៈ ជាអ្នកបើក ខ្លួនជាអ្នកអង្គុយខាងមុខ ហើយមានឈ្មោះ [redacted] វិន, [redacted] ឡាឌីន និង [redacted] ផានី អង្គុយនៅខាងក្រោយ ធ្វើដំណើរពីកែងកំពង់សឹងទៅតាមផ្លូវរក្សជ័យ។ ក្នុងពេលធ្វើដំណើរ អ្នកដេញតាមរថយន្តលួចតាមក្រោយ គេទូរស័ព្ទមកឈ្មោះ [redacted] ឡាឌីន និង [redacted] ផានី ពីទីតាំងរបស់ ឡានលួច ហើយប្រាប់ថាឡាននោះ ជាប្រភេទម៉ាក Prius និងមានហ្វាភ្លើងពីលើដំបូល ។ បន្ទាប់ពីជា ឡាឌីន បាននិយាយទូរស័ព្ទជាមួយអ្នកដេញតាមរថយន្តតាមក្រោយ ហើយ [redacted] រតនៈ បានឃើញឡានចម្ងាយប្រហែល១០០ម៉ែត្រនៅខាងមុខ ដែលមានភិនភាគដូចឡានដែលត្រូវស្ទាក់ ហើយជឹម រតនៈ ក៏បានបត់ឡានដាក់ទទឹងថ្នល់ ហើយខ្លួនមិនទាន់បានចុះឡើយ ដោយ [redacted] រតនៈ [redacted] វិន ជា ឡាឌីន និង [redacted] ផានីបានចុះពីលើឡាន។ ខ្លួនបានឃើញ [redacted] រតនៈ [redacted] វិន ជា ឡាឌីនកាន់កាំភ្លើង។ បន្ទាប់មក ខ្លួនបានលឺសម្លេងស្រែកឱ្យឈប់ៗ និងឃើញតាមកញ្ចក់បង្អួចខាងស្តាំ និងកញ្ចក់ក្រោយ ឃើញ [redacted] ឡាឌីន និង [redacted] រតនៈ រៀដៃឱ្យឈប់ ព្រោះ [redacted] រតនៈ ជឹម វិន ជា ឡាឌីន ឈរនៅខាងក្រោយឡានPick up តែឡានPriusនោះ ជិះក្នុងល្បឿនលឿន ហើយបង្អង់ល្បឿនបន្តិត ភ្លាមនោះក៏បន្ថែមល្បឿនវិញ តាមមុខឡានPick up ពណ៌ស។ ក្រោយពីឡានPrius បានជិះហួសបន្តិច បានលឺសំលេងបាញ់ពីចំហៀងប្រហែល៤ទៅ៥គ្រាប់ ពេលនោះខ្លួនអោនចុះក្រោមនៅក្នុងឡាន ។ បន្ទាប់មកខ្លួនក៏ងើបឡើងវិញ ឃើញ៣ឡានមកដល់ ប្រភេទតូចៗ មានឡានឆ្លាម១ និង២ទៀត មិនស្គាល់ម៉ាក និងឃើញមានគេ (មិនចាំថាអ្នកណា ព្រោះមានមនុស្សច្រើន)ទាញបុរសម្នាក់ទៀតដែលនៅក្នុងឡានPrius ទៅកណ្តាលថ្នល់។ បន្ទាប់មក ខ្លួន និង [redacted] រតនៈ [redacted] វិន បានលើកបុរសដែល បើកឡានPrius ដាក់លើឡានយកទៅមន្ទីរពេទ្យ។

តាមអំណានចម្លើយរបស់ឈ្មោះ [redacted] វណ្ណារិទ្ធ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ កាលពីព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង៣០នាទី រូបខ្លួនបានយករថយន្តរបស់ខ្លួនទៅជួសជុសនៅការ៉ាសឡាន ដែលមានយីហោ [redacted] សុខី លុះដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង៣០នាទីព្រឹក ខ្លួនបានទៅយករថយន្តស្រាប់តែមិនឃើញ ក្រោយមកក៏បានដឹងថា ឈ្មោះ [redacted] សុខី ជិះទៅខេត្តព្រៃវែង ហើយមានរឿងរហូតដល់យករថយន្តរបស់ខ្លួនមករក្សាទុកនៅសាលាដំបូងខេត្តព្រៃវែង។ ខ្លួនសំណូមពរ ស្នើសុំឱ្យតុលាការប្រគល់រថយន្តម៉ាក Toyota Camary ពណ៌ប្រផេះ ផលិតឆ្នាំ ១៩៩៧ ពាក់ផ្លាកលេខ ភ្នំពេញ ២M-៦៣៩៤ មានលេខតួ SXV ២០០០៧៨៧៥៧ លេខម៉ាស៊ីន ៥S៦២៥៤០៨១ ដែលមានខ្លួនជាម្ចាស់កម្មសិទ្ធមកវិញ។

តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ប៊ុនសារៈ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ យថា៖ រូបខ្លួនជាក្មួយជីដូនរបស់ [redacted] សុខី និង [redacted] ផាន់នី។ ដោយឡែក អ្នកផ្សេងទៀតខ្លួនពុំមានជាប់សាច់ញាតិជាមួយឡើយ។ ខ្លួនសុំរក្សាចម្លើយនៅបុស្តិ៍នគរបាលរដ្ឋបាលរក្សជ័យដដែល។ ក្រោយពីសម្រាកពីការងារ នៅកន្លែងជួសជុសរថយន្ត [redacted] ឈិន បានគេទៅ [redacted] សុខី ថាមានចោរលួចឡាន ហើយ [redacted] សុខី អ្នកហៅខ្លួនឱ្យទៅជួយស្ទាក់ឡាន។ នៅពេលទៅដល់កន្លែងកើតហេតុមិនចាំម៉ោងប៉ុន្មាន ឡានដែលខ្លួនជិះទៅជាមួយបានឈប់នៅចម្ងាយប្រហែល១៥ម៉ែត្រពី

ឡាន Pick up ហើយខ្លួនបានចុះពីលើឡានមកក្រៅ ខ្លួនឃើញមានឡាន Pick up បើកភ្លើងហ្វា មានប៉ូលីសប្រហែល៧ទៅ៨នាក់ (មានស្លៀកសំលៀកបំពាក់ឯកសណ្ឋានខ្លះ ស៊ីវិលខ្លះ) មានប្រជាពលរដ្ឋដែរ ហើយឡាន Prius នៅខាងស្តាំដៃខ្លួន (ឡានដែលខ្លួនទៅជាមួយនិងឡាន Prius នៅស្របទិសគ្នា)។ ខ្លួនឃើញ រ៉ាវុធ ឈរអែបឡាន Prius មានប៉ូលីស១(មួយ)នាក់កាន់ ហើយខេមរិន្ទ ឈរនៅខាងស្តាំខាងក្រោយឡាន Prius មានប៉ូលីសម្នាក់កាន់ដែរ។ ក្រោយមកខ្លួនបានលឺសម្លេងបាញ់កាំភ្លើង ០១(មួយ)គ្រាប់ នៅពេលដែលកម្លាំងសមត្ថកិច្ចបានដកកម្លាំងចេញមកវិញ ប៉ុន្តែមិនដឹងថាអ្នកណាជាអ្នកបាញ់ទេ។ ប្រហែលជា៣០(សាមសិប)នាទីក្រោយមក ប៉ូលីសដែលនៅកន្លែងកើតហេតុបាននាំខ្លួនទៅសាកសួរ។ នៅពេលទៅដល់កន្លែងកើតហេតុ បានលឺសម្លេងគេ(មិនដឹងថាអ្នកណា)បាននិយាយថា ឡាន Prius នោះជារបស់ រ៉ាវុធ ដែលដាក់បញ្ចាំនៅ [redacted] ឈិន ។ [redacted] ឈិន បានយកឡាននោះទៅជូលឱ្យចិន ហើយ រ៉ាវុធ បានទៅយកពីចិនមក ដោយគ្មានជូនដំណឹងទៅ [redacted] ឈិន។ ខ្លួនឃើញមានបុរសម្នាក់មិនស្គាល់ឈ្មោះ ដែលមានភិនភាគ សម្បុរស ធាត់ល្មម មិនសូវមានសក់ កម្ពស់ប្រហែល១.៧០ម៉ែត្រ រើសសំបកគ្រាប់ ហើយកាន់ខ្លួនឯង។ ឈ្មោះ [redacted] សុខី មិនបានដឹងថា រ៉ាវុធ ជាអ្នកយកឡាននោះទៅទេ ព្រោះនៅពេលដែលជិះតាមផ្លូវ ផាន់ សុខី និយាយតែពីចោរៗ លួចឡាន មិនបាននិយាយពីឈ្មោះ រ៉ាវុធ ជាអ្នកយកឡើយ។ នៅពេលជិះតាមឡាន ផាន់ សុខី ជាអ្នកទំនាក់ទំនងជាមួយនិង [redacted] ផាន់នី រឿងចោរលួចឡាន។

តាមអំណានចម្លើយរបស់ឈ្មោះ [redacted] ឈុនឡាយ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ខ្លួនជាកូនជាងជួសជុលរថយន្តឱ្យឈ្មោះ [redacted] សុខី រយៈពេលជិត ១ឆ្នាំហើយ។ ខ្លួនសុំរក្សាចម្លើយនៅប៉ុស្តិ៍នគរបាលរដ្ឋបាលរក្សជ័យដដែល។ ខ្លួនមិនបានដឹងទេ ដោយគ្រាន់តែឈ្មោះ ផាន់ សុខី ប្រាប់ខ្លួនថា មានចោរលួចឡាន នៅយានដ្ឋាន [redacted] សុខី ។ ឈ្មោះ [redacted] សុខី បបួលខ្លួនឡើងទៅជាមួយបានជាគ្នា ហើយខ្លួនក៏ព្រមទៅជាមួយ ដោយមានគ្នាសរុប ៤នាក់ គឺ ទី១ វ៉ែន ប៊ុនសារៈ ទី២ [redacted] ឈិន ទី៣ [redacted] សុខី និងទី៤ រូបខ្លួន។ ពេលចេញពីយានដ្ឋាន មានគ្នា ៣នាក់គឺ ទី១ វ៉ែន ប៊ុនសារៈ ទី២ [redacted] សុខី និងទី៣ រូបខ្លួន។ ឈ្មោះ [redacted] ឈិន បានឡើងឡានជិះ ជាមួយក្រុមខ្លួនទាំងបីនាក់ នៅត្រង់ផ្លូវបំបែកទៅរោងចក្រស្រាបៀថៃហ្គ័រ(ស្ថានីយ៍ប្រេងតូតាល់) ដោយឈ្មោះ [redacted] ឈិន ជាអ្នកបើក។ ខ្លួនបានសួរឈ្មោះ [redacted] ឈិន ថា ឡាននោះរបៀបម៉េចវិញ ហើយឈ្មោះ [redacted] ឈិន បាននិយាយប្រាប់ខ្លួនថា វាលួចឡានខ្ញុំ ព្រមទាំងបើកជីភីអេសមើលផងដែរ។ ខ្លួនមិនសូវចូលចិត្តឈ្មោះ [redacted] ឈិន ទេ ដោយសារឈ្មោះនេះជាមនុស្សនិយាយកុហក់ ។ នៅពេលដល់កន្លែងកើតហេតុ ឃើញឡានម៉ាកព្រូស ឆ្លាក់ម្ខាងផ្លូវខាងស្តាំដៃ ដោយមានបែកកញ្ចក់ ទ្វារមុខខាងឆ្វេង ហើយខ្លួនបានដើរត្រឡប់ទៅក្រោយវិញ។ ឈ្មោះ [redacted] សុខី មិនបានដឹងថាឈ្មោះ រ៉ាវុធ ជាអ្នកបើកឡាននោះទេ ព្រោះនៅពេលជិះតាមផ្លូវ [redacted] សុខី និយាយថាចោរលួចឡានៗ មិនបាននិយាយពីឈ្មោះ រ៉ាវុធ នោះឡើយ ។

តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឈិន ,ឈ្មោះ [redacted] ផាន់នី និងឈ្មោះ [redacted] សុខី មានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី នឹងរបាយការណ៍សមត្ថកិច្ច បញ្ជាក់ឲ្យឃើញថា ៖ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ ពិតជាមានអំពើប្លន់បរិហាបង្កាច់កេរ្តិ៍ និងបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍មួយកើតឡើងពិតប្រាកដមែន ដែលអំពើខាង

លើនេះច្បាប់ចាត់ទុកថាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣១១ .៣១២ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

តាមចម្លើយសារភាពរបស់ជនជាប់ចោទ ឈ្មោះ [redacted] ឈិន បានឆ្លើយថា ៖ « ខ្លួនពុំបានប្តឹងថាជនរងគ្រោះ ឈ្មោះ [redacted] រ៉ាវុធ ជាចោរលួចឡានទេ ខ្លួនគ្រាន់តែឆ្លើយថា ឲ្យឈ្មោះ [redacted] សុខី ជួយស្ទាក់ចាប់ឡាន របស់ខ្លួនផង ការឆ្លើយដោះសារនេះ ត្រូវបានបដិសេធចោល ដោយជនជាប់ចោទឈ្មោះ [redacted] សុខី និងឈ្មោះ [redacted] ផានី ថា » ឈ្មោះ [redacted] ឈិន បានប្រាប់មកខ្លួនថា ឲ្យជួយស្ទាក់ចាប់ឡាន ម៉ាកព្រូស ពណ៌ទឹកមាស ផ្លាកលេខ ភ្នំពេញ 2AF-2679 នេះផង ព្រោះចោរ លួចយកទៅហើយ ដោយឮពាក្យថាចោរ លួចទើបពួកខ្លួន បានប្តឹងបន្តទៅ សមត្ថកិច្ចពួនស្ទាក់ បង្ក្រាបរហូតដល់ផ្ទុះអាវុធ សម្លាប់ជនរងគ្រោះ ។ ដែលសមត្ថកិច្ចទាំងពីរនាក់ មានឈ្មោះ [redacted] រតនៈ និងឈ្មោះ [redacted] វិន ត្រូវបានចៅក្រមស៊ើបសួរ ចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះពីបទៈ ឃាតកម្ម ។ ដោយសារការប្តឹងបង្កាច់កេរ្តិ៍ ដោយចោទប្រកាន់ជនរងគ្រោះ ជាចោរ នេះហើយហៅថា ប្តឹង បរិហាបង្កាចកេរ្តិ៍ ទើបឈានដល់ប្រព្រឹត្ត បទឧក្រិដ្ឋ ដែលបណ្តាលឲ្យស្លាប់ មនុស្ស ដោយសារអំពើប្រព្រឹត្តរបស់ជនជាប់ចោទ ទាំងបី ទើបបទឧក្រិដ្ឋ (ឃាតកម្ម ) មួយកើតឡើង ដោយបានសម្រេច ។ អំពើនេះចាត់ទុកជាបទល្មើសញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋជាអាទិ៍ ដូចមានចែងក្នុងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

តាមមាត្រា៣១១ បានចែងថា« ការប្តឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើប្តឹងបរិហាអំពីអំពើដែលគេដឹងថា មិនពិត ហើយដែលនាំឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ កាលបើការប្តឹងបរិហារនេះត្រូវផ្ញើទៅដល់:

. អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការ ដូចជាចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជក ឬ
. បុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច។ »

ដែលអំពើនេះត្រូវបានផ្តន្ទាទោសតាមបញ្ញាតិមាត្រា៣១២ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០០.០០០៛(មួយសែន)រៀល ទៅ២.០០០.០០០៛(ពីរលាន)រៀល។

ចំណែកមាត្រា៤៩៥ បានចែងថា«បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ គឺជាអំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយដែលមានចែង« ការនៅក្នុងមាត្រា៤៩៤ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១.០០០.០០០៛(មួយលាន)រៀល ទៅ៤.០០០.០០០៛(បួនលាន)រៀល។

មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ឈិន ភេទប្រុស , ឈ្មោះ [redacted] ផានី ភេទប្រុស និងឈ្មោះ [redacted] សុខី ភេទប្រុស ពីបទៈ ប្តឹងបរិហាបង្កាច់កេរ្តិ៍ និងបទ. ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅចំណុចភូមិគោកសណ្តែក ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣១១. ៣១២ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-អំពើរបស់ជនជាប់ចោទទាំង០៣នាក់ ក្នុងការប្តឹងបរិហាបង្កាច់កេរ្តិ៍ នេះបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ រហូតដល់មានការបាត់បង់ជីវិតរបស់អ្នកដទៃ ។

-ជនជាប់ចោទទាំង០៣នាក់ ជានីតិជន មានស្មារតីគ្រប់គ្រាន់ និងមានកាយសម្បទាពេញលេញពុំឃើញមានសញ្ញាណាមួយបញ្ជាក់ថាមានស្មារតីវិប្បល្លាសឡើយ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន និង ប្តឹងសុំឲ្យ ផ្តន្ទាទោសជនជាប់ចោទទៅ តាមច្បាប់ គឺមានហេតុផលសមស្រប គប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំង ០៣នាក់ ថា ជនរងគ្រោះ និងកូនក្តីខ្លួនមានទំនាក់ទំនងគ្នា រហូតធ្វើឲ្យកូនក្តីខ្លួនយកឡានទៅជួលឲ្យជនជាតិចិនទៀត។ ការប្តឹងរបស់កូនក្តីខ្លួនមិនមែនជាបរិហាបង្កាច់កេរ្តិ៍ទេ។ ចំណែកការចោទពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ គឺគ្រាន់តែជាការប្តឹងតៗគ្នាប៉ុណ្ណោះ ដូចនេះក្នុងរឿងនេះវាខ្វះធាតុផ្សំ នៃបទល្មើសបានសេចក្តីថា បើខ្វះចំណុចណាមួយ មិនអាចចាត់ទុកថាជាបទល្មើសបានឡើយ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួន រួចខ្លួនពីបទចោទប្រកាន់ ការលើកឡើងនេះតុលាការពុំអាចលើកមកពិចារណាតាមការប្តឹងសុំរបស់លោកមេធាវីឡើយ ដោយហេតុថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំង០៣នាក់ គឺពិតជាបានធ្វើឲ្យមានភាពវឹកវរយ៉ាងធ្ងន់ធ្ងរដល់សន្តិសុខសង្គម ដោយសារតែការប្តឹងបរិហារបង្កាច់កេរ្តិ៍របស់ខ្លួននេះហើយទើប ឈានទៅដល់ការបាញ់សម្លាប់ មនុស្សថែមទៀតផង ។ ដែលអំពើខាងលើនេះមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដូចមានក្នុងបញ្ញត្តិមាត្រា ៣១១. ៣១២ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ១/ ឈ្មោះ [redacted] ឈិន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ជាតិខ្មែរ មុខរបរ ៖ ជាងឡាន សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កំរិតវប្បធម៌ ថ្នាក់ទី៣ ឪពុកឈ្មោះ [redacted] ហឿន (រ) ម្តាយឈ្មោះ [redacted]រិន (ស) ប្រពន្ធឈ្មោះ [redacted] ហ៊ាង(រ) មានកូន០០នាក់ ជានីតិជន ទោសពីមុនគ្មាន(ឃុំថ្ងៃទី២៨.០៣.២០១៩

២-ឈ្មោះ [redacted] សុនី ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ៖ ជាងជួសជុលរថយន្តសាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កំរិតវប្បធម៌ ថ្នាក់ទី១០ថ្មី ឪពុកឈ្មោះ [redacted] សុភាព (រ) ម្តាយឈ្មោះ [redacted] សំអូន (ស) ប្រពន្ធឈ្មោះ [redacted] ហ៊ាង (រ) មានកូន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន(ឃុំថ្ងៃទី២៨.០៣.២០១៩)។

៣-ឈ្មោះ [redacted] ជានី ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរ ៖ កសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តព្រៃវែង កំរិតវប្បធម៌ ថ្នាក់ទី១២ថ្មី ឪពុកឈ្មោះ [redacted] សុភាព (រ) ម្តាយឈ្មោះ [redacted] សំអូន (ស) ប្រពន្ធឈ្មោះ [redacted] ចាន់នុត (រ) មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន(ឃុំថ្ងៃទី២៨.០៣.២០១៩) ។

-ពីបទៈប្តឹងបរិហាបង្កាច់កេរ្តិ៍ និងបទ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅចំណុច



Scanned with CamScanner

ភូមិគោកសណ្តែក ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃ២៣ ខែមីនា ឆ្នាំ២០១៩ បទល្មើស ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣១១.៣១២ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។

_ ដើមបណ្តឹងរដ្ឋប្បវេណី បានដកពាក្យបណ្តឹងឈប់ប្តឹងទាមទារសំណង លើជនជាប់ចោទ និងមិនទាមទារ អ្វីទៀតនោះដែរ ដូច្នេះតុលាការពុំចាំបាច់លើកយកមកពិចារណាពីបញ្ហាសំណងរដ្ឋប្បវេណីតទៅទៀតនោះឡើយ។

_ តាមពាក្យស្នើសុំរថយន្ត ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុខខី ឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ដារ៉ា ដែលអះអាងថា ជាប្រពន្ធ ,ជាម្តាយ និងជាឪរបស់ជនរងគ្រោះ ហើយតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំយករថយន្តម៉ាកព្រូស ពណ៌ទឹកមាស ពាក់ស្លាកលេខ 2AF -2679 ថាជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] រ៉ាវុធ ជាជនរងគ្រោះ យកទៅប្រើប្រាស់វិញនោះ ឃើញថា ពុំបានដាក់ឯកសារណាដែលជាភស្តុតាង ដើម្បីបញ្ជាក់ថា រថយន្តខាងលើជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] រ៉ាវុធ ឡើយ ដូចនេះការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី នេះ តុលាការពុំលើកយកមកពិចារណាទេ ។ ដោយហេតុថា តាមការអះអាងរបស់ឈ្មោះ [redacted] លីណា នៅដំណាក់កាលដេញដោលនាពេលសវនាការ ថា កន្លងមកខ្លួន និងឈ្មោះ [redacted] រ៉ាវុធ ធ្លាប់ជាសង្សារនឹងគ្នា ហើយឈ្មោះ [redacted] រ៉ាវុធ នេះក៏ធ្លាប់យករថយន្តម៉ាកព្រូស ពណ៌ទឹកមាស ស្លាកលេខ 2AF -2679 នេះ យកទៅដាក់បញ្ចាំគេនៅម្តុំផ្សារឃ្លាំងរំសេវ ដោយខ្លួន បានដើររកឃើញ ហើយលូសពីកន្លែងដាក់បញ្ចាំ វិញ អស់ចំនួន ៣០០០០$ (បីពាន់ដុល្លារ ) ម្តងរួចហើយ ។ ក្រោយមកមុនពេលកើតហេតុពីរខែ (ពីរខែ ) ឈ្មោះ យ៉ន រ៉ាវុធ បានទៅជួបខ្លួនម្តងទៀត ពេលសុំទិញ រថយន្តម៉ាកព្រូស នេះ ពីខ្លួនក្នុងតម្លៃ ១២០០០$ (មួយម៉ឺនពីរពាន់ដុល្លារ ) ហើយសុំកក់ ២៥០០$ សិន ដោយរថយន្តនេះចេញបាត់រហូតដល់ពេលកើតហេតុទើបខ្លួនដឹង ។

_តាមឯកសារជាលិខិតលក់ទិញរថយន្ត ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ.២០១៥ និងតារាងបង់ប្រាក់រំលូសចេញដោយ មីក្រូហិរញ្ញវត្ថុ ពិភពថ្មី ឃើញថា រថយន្តនេះនៅបន្តបង់ប្រាក់រំលូសរហូតដល់ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២០ ដែលម្ចាស់កម្មសិទ្ធិជារបស់ឈ្មោះ [redacted] លីណា ពិតប្រាកដមែន ដូចនេះតុលាការគប្បីប្រគល់រថយន្តម៉ាក TOYOTA BRIUS ពណ៌ទឹកមាស ផ្លាកលេខ ភ្នំពេញ 2AF-2679 មានលេខម៉ាស៊ីន1NZU167080 លេខតួ JIDKB20U677628860 ឲ្យទៅម្ចាស់ដើមវិញ ។

.តាមឯកសារដែលបានដាក់ជូនតុលាការ ក៏ដូចជាដីកាសម្រេចប្រគល់វត្ថុតាងដែលចាប់យក លេខ៩៥១ ដស.ព្រទ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរររថយន្តម៉ាក TOYOTA CAMRY ពណ៌ប្រផេះ ផ្លាកលេខភ្នំពេញ 2M-6394 មានលេខម៉ាស៊ីនENGINE NO: 5S6 254081 លេខតួFRAME SXV200078757 ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] វណ្ណរិទ្ធ ដូចនេះតុលាការគប្បីប្រគល់ឲ្យទៅឈ្មោះ [redacted] វណ្ណរិទ្ធ ដែលជាម្ចាស់ដើមវិញ។

. ផ្អែកតាមឯកសារ គឺពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ដែលបានដាក់ជូនតុលាករនៅដំណាក់ចៅក្រមស៊ើបសួរ ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី បានដកពាក្យឈប់ប្តឹងលើជនជាប់ចោទទាំង០៣នាក់ តទៅទៀតដោយ ដោយហេតុថា បានទទួលសំណងរួចរាល់ ហើយ ដូចនេះបញ្ហាសំណងរដ្ឋប្បវេណី តុលាការពុំលើកយកមកពិចារណាឡើយ។

## ហេតុដូច្នេះ

## ទនិច្ឆ័យ សេចក្ត

១.ផ្តន្ទាទោស

១.១_ ឈ្មោះ [redacted] ឈិន ភេទប្រុស អាយុ២៥ឆ្នាំ មុខរបរ: ជាងជួសជុលរថយន្ត (មានអត្តសញ្ញាណដូចខាងលើ)ដាក់ពន្ធនាគារកំណត់រយៈពេល១៣ (ដប់បី) ខែ និងពិន័យចំនួន ១.០០០.០០០៛(មួយលាន)រៀល បង់ចូលជាថវិការដ្ឋ។

១.២_ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរ: កសិករ (មានអត្តសញ្ញាណដូចខាងលើ)ដាក់ពន្ធនាគារកំណត់រយៈពេល ១៣ (ដប់បី) ខែ និងពិន័យចំនួន ១.០០០.០០០៛(មួយលាន) រៀល បង់ចូលជាថវិការដ្ឋ។

១.៣_ ឈ្មោះ [redacted] សុខី ភេទប្រុស អាយុ៣១ឆ្នាំ មុខរបរ: ជាងជួសជុលរថយន្ត (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១៣ (ដប់បី) ខែ និងពិន័យចំនួន ១.០០០.០០០៛(មួយលាន)រៀល បង់ចូលជាថវិការដ្ឋ។

ពីបទ៖ ប្លន់បរិហាបង្កាច់កេរ្តិ៍ និងបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅចំណុចភូមិគោកសណ្តែក ឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃ២៣ ខែមីនា ឆ្នាំ២០១៩ បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣១១.៣១២ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។

**២/ ប្រគល់វត្ថុចាប់យក ជា:**

ក. រថយន្តម៉ាក TOYOTA BRIUS ពណ៌ទឹកមាស ផ្លាកលេខ ភ្នំពេញ 2AF-2679 មានលេខម៉ាស៊ីន1NZU167080 លេខតួ JIDKB20U677628860 ប្រគល់ឲ្យឈ្មោះ [redacted] លីណា ដែលជាម្ចាស់ដើមវិញ។

ខ. រថយន្តម៉ាក TOYOTA CAMRY ពណ៌ប្រផេះ ផ្លាកលេខ ភ្នំពេញ 2M-6394 មានលេខម៉ាស៊ីនENGINE NO:5S6254081 លេខតួFRAME SXV200078757 ប្រគល់ឲ្យឈ្មោះ [redacted] វណ្ណរិទ្ធ ដែលជាម្ចាស់ដើមវិញ។

_សាលក្រមនេះជំនុំជម្រះនៅថ្ងៃពុធ ០៣រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈិន ឈ្មោះ [redacted] ផានី ឈ្មោះ [redacted] សុខី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

_ទុកសិទ្ធិឲ្យប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]